# កម្មសិក្សានិពន្ធអត្ថបទសាច់រឿងភាពយន្តឯកសារ

## ភ្នំពេញ - ប្រទេសកម្ពុជា / ថ្ងៃទី២២ ខែកុម្ភៈ – ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៦

# សេចក្តីប្រកាសជ្រើសរើស

កាលបរិច្ឆេទឈប់ទទួលពាក្យ៖ ថ្ងៃទី២៣ ខែមករា



**កម្មវិធីដែលឧបត្ថម្ភដោយវិទ្យាស្ថានបារាំងប្រទេសវៀតណាម និងកម្ពុជា វិទ្យាស្ថាន Goethe នៃប្រទេសវៀតណាម និងមូលនិធិអាល្លឺម៉ង់-បារាំងដើម្បីវប្បធម៌**

*តើគំនិតមួយក្លាយជាគម្រោងភាពយន្តឯកសារដោយរបៀបណា? តើត្រូវបង្កើតរឿង និងទស្សនៈប្រកបដោយសោភ័ណភាពសិល្បៈដែលអ្នកនិពន្ធមានដោយរបៀបណា? តើគម្រោងមួយក្លាយជាអត្ថបទសាច់រឿងដោយរបៀបណា? តើភាពយន្តដែលមនុស្សស្រមៃចង់បានអាចក្លាយជាការពិតដោយរបៀបណា?*

ចំណុចទាំងនេះគឺជាសំណួរសំខាន់មួយចំនួននៃការផលិតភាពយន្តឯកសារ ដែលត្រូវតែឆ្លើយជាអាទិភាព ឬយ៉ាងហោចណាស់បំភ្លឺដោយការនិពន្ធអត្ថបទសាច់រឿង។ ចំណុចនេះក៏មានន័យដែរថា ម្ចាស់គម្រោងមិនបន្តនៅឯកោទៀតឡើយ និងថា ចាប់តាំងពីដំបូង ម្ចាស់គម្រោងប្រឈមនឹងការយល់ឃើញរបស់អ្នកដទៃ៖ វាជាការពិតដែលថាការនិពន្ធគឺជាសកម្មភាពស្ងិតស្ងាញមួយ ប៉ុន្តែការផលិតភាពយន្តត្រូវការកិច្ចខិតខំប្រឹងប្រែងរួម។ ដោយផ្អែកលើគំនិតនេះ យើងកំពុងស្វែងរកអ្នកនិពន្ធ/អ្នកផលិតភាពយន្តឯកសារមានទេពកោសល្យ ដើម្បីចូលរួមនៅក្នុងកម្មសិក្សា Asiadoc នេះនៅទីក្រុងហាណូយ។

## A. ការរៀបចំ និងការដំឡើង

<u>សេចក្តីសង្ខេបត្រួសៗ</u>

**អ្នកនិពន្ធ/អ្នកផលិតភាពយន្តឯកសារនៅអាស៊ីអាគ្នេយ៍* ចំនួនចាប់ពី ៦ ទៅ ១២ នាក់**នឹងត្រូវបានទទួលឲ្យចូលរួមនៅក្នុងកម្មសិក្សារៀននិពន្ធសម្រាប់សិក្ខាសាលារយៈពេលពីរសប្តាហ៍ ដែលមានគោលដៅ៖

- អនុវត្តវិភាគបែបស្ថាបនាស៊ីជម្រៅ និងបែបវិនិច្ឆ័យលើគម្រោងរបស់ខ្លួន
- បង្កើតអត្ថបទសាច់រឿងភាពយន្តឯកសារជាក់ស្តែងសម្រាប់គម្រោងរបស់ខ្លួន
- និងជាចុងក្រោយ ធ្វើការហាត់សមនៅក្នុងការរៀបចំភាពយន្តជាវីដេអូព្រាង

****សូមកត់សម្គាល់ថា អ្នកនិពន្ធវៀតណាមមិនមានសិទ្ធិចូលរួមនៅក្នុងសិក្ខាសាលានេះទេ។***

<u>ការដំឡើង</u>

កម្មសិក្សានឹងធ្វើឡើងនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា នៅមជ្ឈមណ្ឌលបុប្ផាណា **ចាប់ពីថ្ងៃទី២២ ខែកុម្ភៈ ដល់ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៦***។ គ្រូបណ្តុះបណ្តាលម្នាក់មកពីប្រទេសអាល្លឺម៉ង់ ដែលជាអ្នកនិពន្ធផង និងជាអ្នកដឹកនាំ

រឿងផង នឹងធ្វើបទឧទ្ទេសនាមកម្មវិធីនេះ។ គ្រូបណ្តុះបណ្តាលម្នាក់មកពីប្រទេសបារាំងអាចនៅអមជាមួយគាត់ផងដែរប្រសិនបើគម្រោងចំនួន ១២ ត្រូវបានជ្រើសរើសជាស្ថាពរ។
**សូមកត់សម្គាល់ថា កាលបរិច្ឆេទអាចមានការផ្លាស់ប្តូរ និងត្រូវបានបញ្ជាក់មួយខែមុនយ៉ាងតិច។*

<u>កម្មវិធី</u>

ការសិក្សាជាក្រុមរួម ដោយមានការសម្របសម្រួលពីគ្រូបណ្តុះបណ្តាលសម្រាប់គម្រោងនីមួយៗនឹងរួមបញ្ចូលៈ

- ការវិភាគស៊ីជម្រៅនៃសំណួរទាក់ទងនឹង "ខ្លឹមសារ" និងទម្រង់។ ការពិនិត្យមើលរួមគ្នាលើស្នាដៃមុនៗរបស់សិក្ខាកាម ព្រមទាំងភាពយន្តបានមកពីមរតកភាពយន្តឯកសារ
- ការងារស្រាវជ្រាវផ្ទាល់ខ្លួនៈ ការពិនិត្យនិងការបកស្រាយភាពយន្តដែលទាក់ទងនឹងមូលបទ និងបញ្ហាប្រឈមផ្លូវការរបស់គម្រោង
- ការរៀនផ្ទាល់ជាមួយគ្រូៈ ការវិភាគ ការរៀបចំដើម្បីស្វែងរកទីតាំងប្រសិនបើពាក់ព័ន្ធ ការពិនិត្យជម្រើសដែលអាចមានផ្សេងៗមុនពេលស្វែងរកទីតាំង
- ការសមថតភាពយន្ត
- ដំណាក់កាលទីមួយនៃការសរសេរគម្រោង
- ការវិភាគរួមគ្នា និងដាច់ដោយឡែកពីគ្នាលើគម្រោងដែលត្រូវបានសិក្សាឡើងវិញ ក្រោយការស្រាវជ្រាវ និងការស្វែងរកទីតាំង
- សេចក្តីព្រាងចុងក្រោយនៃគម្រោង ដោយមានការសម្របសម្រួលជានិច្ចជាមួយគ្រូបណ្តុះបណ្តាល។

គម្រោងភាពយន្តឯកសារដែលត្រូវបានបង្កើតភាគច្រើននឹងមានឱកាសចូលរួមក្នុងកិច្ចប្រជុំសហផលិតកម្ម ដែលនឹងធ្វើឡើងនៅរាជធានីភ្នំពេញក្រោយកម្មសិក្សាបន្តិច។ អ្នកផលិតភាពយន្តអាចបង្ហាញគម្រោងរបស់ខ្លួនដល់ផលិតករ និងពិធីករមកពីអាស៊ីអាគ្នេយ៍ និងអឺរ៉ុប។

## B. លក្ខខណ្ឌនៃការចូលរួម

<u>គម្រោង</u>

**គម្រោង ដែលនឹងត្រូវបានពិចារណាសម្រាប់ការជ្រើសរើស គឺជា "ភាពយន្តឯកសារច្នៃប្រឌិត"។**
> *"ភាពយន្តឯកសារច្នៃប្រឌិត"៖ ការងារដែលបង្ហាញអំពីតថភាពកាលពីអតីតកាល ឬបច្ចុប្បន្នកាល ដែលជាកម្មវត្ថុ*

*នៃការស្រាវជ្រាវ ការវិភាគ និងការនិពន្ធ ហើយដែលបង្ហាញអំពីភាពដើមនៃចក្ខុវិស័យរបស់អ្នកនិពន្ធ-អ្នកដឹកនាំរឿង។*

**វគ្គសិក្សាត្រូវបានរៀបចំឡើងដើម្បីបង្កើតគម្រោង (ការស្រាវជ្រាវ ការនិពន្ធ ការស្វែងរកទីតាំង យុទ្ធសាស្ត្រផលិត ។ល។)។**

<u>សិក្ខាកាម</u>

- វគ្គសិក្សាត្រូវបានរៀបចំឡើងសម្រាប់អ្នកនិពន្ធ-អ្នកផលិតភាពយន្តមកពី**អាស៊ីអាគ្នេយ៍** (មានអាយុយ៉ាងតិច ១៩ ឆ្នាំ) លើកលែងប្រទេសវៀតណាមចេញ។
- **មិនទាមទារការមានសញ្ញាបត្រ** ប៉ុន្តែ យ៉ាងហោចណាស់ ត្រូវមានបទពិសោធន៍ខ្លះៗលើវិស័យផលិតភាពយន្ត (វិជ្ជាជីវៈ ឬមិនមែនវិជ្ជាជីវៈ) ដែលទាក់ទងនឹងរូបភាព (ការចាក់ផ្សាយ ការថតរូប សិល្បៈទស្សនីយភាព...) ឬការនិពន្ធ (ល្ខោន ស្នាដៃអក្សរសិល្ប៍...) ជាការប្រសើរ។ គ្រូបណ្តុះបណ្តាលនឹងសម្របទៅតាមដំណាក់កាលបង្កើតគម្រោង និងបទពិសោធន៍របស់សិក្ខាកាម ដើម្បីផ្តល់ជំនួយតាមកម្រិតពាក់ព័ន្ធ ដែលសិក្ខាកាមទាំងនេះត្រូវការដើម្បីពង្រឹងគម្រោងរបស់ខ្លួន។ <u>អ្នកមិនទាន់ចេះសោះ និងអ្នកមានបទពិសោធន៍លើវិស័យផលិតភាពយន្តអាចដាក់ពាក្យបាន</u>។
- **គម្រោងគួរត្រូវបានបង្ហាញដោយអ្នកនិពន្ធ/អ្នកផលិតភាពយន្ត** ទោះបីជាគម្រោងទាំងនោះមាន ឬគ្មានផលិតករក៏ដោយ។
- ចាំបាច់ត្រូវមានជំនាញទំនាក់ទំនងល្អជាភាសាអង់គ្លេស។

<u>ការជ្រើសរើសបេក្ខជន</u>

**ពាក្យសុំមិនពេញលេញមិនត្រូវបានពិចារណាឡើយ។** គណៈកម្មាធិការនឹងមិនពន្យល់អំពីមូលហេតុនៃការសម្រេចចិត្តរបស់ខ្លួនប្រាប់ដល់បេក្ខជនដែលធ្លាក់ឡើយ។ លទ្ធផលនឹងផ្ញើតាមអ៊ីមែលយ៉ាងហោចណាស់បីសប្តាហ៍មុនពេលចាប់ផ្តើមកម្មសិក្សា។

<u>សោហ៊ុយនៃកម្មវិធី</u>

កម្មវិធីនេះគឺមិនគិតថ្លៃសម្រាប់អ្នកនិពន្ធភាពយន្តដែលត្រូវបានជ្រើសរើសសម្រាប់កម្មសិក្សា ដែលរួមមាន៖

- ថ្លៃបង្រៀន
- ការចូលមើលឯកសារ (ភាពយន្ត ការរិះគន់ស្ថាបនា ។ល។)

- ការប្រើប្រាស់បរិក្ខារថត
- អាហារ និងភេសជ្ជៈ
- កន្លែងស្នាក់នៅ
- ថ្លៃធ្វើដំណើរ

ការដាក់ពាក្យសុំ

ពាក្យសុំ រួមបញ្ចូលទាំងទម្រង់ដែលត្រូវបានបំពេញរួច និងឯកសារតម្រូវនានា (សូមមើលបញ្ជីខាងក្រោម) ត្រូវតែផ្ញើ **តែតាមអ៊ីមែលប៉ុណ្ណោះ** និងឲ្យបានមុន **ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥** – ម៉ោង ១២ ពាក់កណ្តាលអាធ្រាត (កាលបរិច្ឆេទឈប់ទទួលពាក្យ) មកកាន់អាសយដ្ឋានដូចខាងក្រោម (ពាក្យសុំត្រូវតែផ្ញើជា**ភាសាអង់គ្លេស**)៖


Frédéric Violeau / ASIADOC / Docmonde

*Le Village - 07170 Lussas (France)*

*ទូរសព្ទ៖ 00 33 4 75 37 93 51*

អ៊ីមែល៖ lumieremondediff@gmail.com


ឯកសារតម្រូវ៖

1. ទម្រង់ពាក្យសុំ (សូមមើលខាងក្រោម)
2. ប្រវត្តិរូបសង្ខេបលម្អិតភ្ជាប់ជាមួយនឹងរូបថតមួយសន្លឹករបស់អ្នកនិពន្ធ-អ្នកផលិតភាពយន្ត
3. លិខិតបញ្ជាក់ចំណាប់អារម្មណ៍របស់អ្នកដឹកនាំរឿង និងសាច់រឿងសង្ខេបដែលត្រូវបានបង្កើតពី ២ ដល់ ១០ ទំព័រ

សូមសរសេរឲ្យបានច្បាស់នៅលើទំព័រទាំងអស់នៃឯកសាររបស់អ្នកនូវ**ឈ្មោះគម្រោង** និង**ឈ្មោះអ្នកនិពន្ធ**។

## 1. ទម្រង់ពាក្យសុំ

*ការនិពន្ធអត្ថបទសាច់រឿងភាពយន្តឯកសារនៅប្រទេសវៀតណាម*

**- ឈ្មោះគម្រោង៖**

**- ប្រវែងគ្រោងទុក៖**

**- សេចក្តីសង្ខេប (១០ បន្ទាត់)៖**

**- ផលិតករសក្តានុពលនៃគម្រោងនេះ៖**

**- បេក្ខជនសម្រាប់កម្មវិធី – អ្នកនិពន្ធ-អ្នកដឹកនាំរឿងនៃគម្រោង៖**

| | |
|---|---|
| នាមត្រកូល៖ | នាមខ្លួន៖ |
| ថ្ងៃខែឆ្នាំកំណើត៖ | ភេទ៖ |
| អាសយដ្ឋាន៖ | |
| លេខកូដប្រៃសណីយ៍ ទីក្រុង៖ | ប្រទេស៖ |
| ទូរសព្ទ៖ | ទូរសារ៖ |
| ទូរសព្ទដៃ៖ | អ៊ីមែល៖ |
| សញ្ជាតិ៖ | ភាសាកំណើត៖ |
| ចំណេះដឹងផ្នែកភាសាលើការនិយាយ៖ | |
| កម្រិតវប្បធម៌៖ | |
| បទពិសោធន៍ផលិតភាពយន្ត / និពន្ធអត្ថបទសាច់រឿង៖ | |
| តើគម្រោងនេះធ្លាប់បានទទួលប្រយោជន៍ពីសិក្ខាសាលា / កម្មសិក្សាផ្សេងទៀតហើយឬនៅ? ប្រសិនបើធ្លាប់ តើសិក្ខាសាលា / កម្មសិក្សាមួយណា (ទីកន្លែង កាលបរិច្ឆេទ ឈ្មោះគ្រឹះស្ថាន ឈ្មោះគ្រូបណ្តុះបណ្តាល...)? | |

2. ប្រវត្តិរូបសង្ខេបលម្អិតភ្ជាប់ជាមួយនឹងរូបថតមួយសន្លឹករបស់អ្នកនិពន្ធ-អ្នកផលិតភាពយន្ត

3. លិខិតបញ្ជាក់ចំណាប់អារម្មណ៍របស់អ្នកដឹកនាំរឿង និងសាច់រឿងសង្ខេបដែលត្រូវបានបង្កើតពី ២ ទៅ ១០ ទំព័រ

**កាលបរិច្ឆេទ និងហត្ថលេខា៖**